ក្រសួងពាណិជ្ជកម្ម

លេខ ០៨៩ ព.ណ.ភ.ក.អបប.ប្រក

# ប្រកាស
# ស្តីពី
# ស្លាកសញ្ញាហាឡាលកម្ពុជា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា១០ មាត្រា១១ មាត្រា១៣ មាត្រា១៦ មាត្រា១៩ មាត្រា២៤ និងមាត្រា២៦ នៃអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពី **ស្លាកសញ្ញាហាឡាលកម្ពុជា** ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងផលិតផលហាឡាលកម្ពុជា ស្របតាមបច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ដើម្បីលើកកម្ពស់ទំនុកចិត្តដល់អ្នកប្រើប្រាស់ និងជំរុញការនាំចេញ។

**ប្រការ២.-**

ស្លាកសញ្ញាហាឡាលកម្ពុជា អាចប្រើប្រាស់លើសេវាកម្ម ការផលិត និងការវេចខ្ចប់ ផលិតផលហាឡាល បន្ទាប់ពីទទួលបានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា។

**ប្រការ៣.-**

បុគ្គលស្នើសុំប្រើប្រាស់ស្លាកសញ្ញាហាឡាលកម្ពុជា ត្រូវប្រើប្រាស់ស្លាកសញ្ញានេះ ឱ្យបានត្រឹមត្រូវ ដូចបានកំណត់ក្នុងប្រការ៤ និងមាននៅក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

**ប្រការ៤.-**

ស្លាកសញ្ញាហាឡាលកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម៖

១. មានរាងមូល ដែលមានផ្ទៃពណ៌ស អក្សរពណ៌បៃតងចាស់ និងព័ទ្ធដោយខ្សែពណ៌ខ្មៅ។

២. រង្វង់មូលផ្ទៃមានអក្សរពណ៌បៃតងចាស់ព័ទ្ធ ជាពណ៌ដែលសាសនិកឥស្លាមនិងប្រជាជាតិអារ៉ាប់និយមប្រើ តំណាងឱ្យកម្រាលព្រំដែលមានភាពស្រស់ស្អាត ដូចមានក្នុងគម្ពីរកូរ៉ាន និងតំណាងឱ្យភាពអព្យាក្រឹត្យ មិនលម្អៀង ត្រឹមត្រូវ និងស្មើភាព។

៣. អក្សរជាខេមរភាសា គឺ «ព្រះរាជាណាចក្រកម្ពុជា» និងជាភាសាអង់គ្លេស គឺ «KINGDOM OF CAMBODIA» ជាឈ្មោះរបស់ប្រទេសកម្ពុជា ដែលជាដែនសមត្ថកិច្ចក្នុងការគ្រប់គ្រង អង្កេតស្រាវជ្រាវ និងត្រួតពិនិត្យ។

៤. ក្បាច់ផ្កាចន្ទន៍ អមពាក់កណ្តាល ជាប្រភេទផ្កាម្យ៉ាងនៃរុក្ខជាតិហូបផ្លែមួយប្រភេទដែលមានរាងមូលពណ៌លឿង និងមានក្លិនក្រអូបស្រាល។ ក្បាច់ផ្កានេះ ត្រូវបានគេឃើញនៅលើចម្លាក់នៃប្រាសាទអង្គរវត្ត និងមានរចនាបថជាប្រពៃណីខ្មែរ។ ផ្កាចន្ទន៍ ក៏តំណាងឱ្យសុភមង្គល និងសុខដុមភាព។

៥. ហាឡាល ឬ HALAL ឬ حلال សំដៅដល់វត្ថុណាមួយ ឬសេវាកម្មណាមួយ ដែលអនុញ្ញាតឱ្យប្រើប្រាស់ ឬឱ្យចូលរួម ដោយអាស្រ័យទៅតាមច្បាប់ឥស្លាម។

៦. អក្សរហាឡាលកម្ពុជា ឬ HALAL CAMBODIA សំដៅដល់សេវាកម្ម ការផលិត និងការវេចខ្ចប់ផលិតផលហាឡាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៧. អក្សរឥស្លាម المجلس الأعلى للشؤون الإسلامية في كمبوديا គឺគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា សំដៅដល់ចាងហ្វាងនៃគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា។

**ប្រការ៥.-**

ស្លាកសញ្ញាហាឡាលកម្ពុជា ត្រូវមានពណ៌បៃតងចាស់ ជាពណ៌ដើមផ្លូវការ ដូចមាននៅក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។ ក្នុងករណី មិនអាចប្រើប្រាស់ពណ៌ដើមបាន ឬមានបំណងផ្លាស់ប្តូរពណ៌ទៅតាមរដូវកាល ឬ

ព្រឹត្តិការណ៍ណាមួយ បុគ្គលស្នើសុំប្រើប្រាស់ស្លាកសញ្ញាហាឡាលកម្ពុជា ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

សមាសភាពគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ប្រធានក្រុមឯកទេសផលិតផលហាឡាល និងប្រតិបត្តិករអាជីវកម្មផលិតផលហាឡាល ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៥កើត ខែផល្គុន ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធាន**

**គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ០៧៨ ពណ.សកបប.ប្រកចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣**
**ស្ដីពីស្លាកសញ្ញាហាឡាលកម្ពុជា**

លេខកូដពណ៌ប្រើប្រាស់លើស្លាកសញ្ញាហាឡាលកម្ពុជា

- Black: K100
- Green: C100 Y100
- White: 0

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# ពាក្យស្នើសុំអនុញ្ញាតប្ដូរពណ៌ស្លាកសញ្ញាហាឡាលកម្ពុជា

| (សំរាប់មន្ត្រីប្រើប្រាស់ប៉ុណ្ណោះ) | |
|---|---|
| លេខដាក់ពាក្យ: | |
| កាលបរិច្ឆេទដាក់ពាក្យ: | |

## ផ្នែកទី១ : ព័ត៌មានអ្នកស្នើសុំ

គោត្តនាម និងនាម ៖ ................................................ភេទ.....................អាយុ...............ឆ្នាំ

អាសយដ្ឋាន ៖.......................................................................................................

.......................................................................................................

អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន៖...........................................................................

ឈ្មោះអាជីវកម្ម ៖.........................................................តួនាទី៖..........................

អាសយដ្ឋានអាជីវកម្ម ៖.......................................................................................

.......................................................................................................

ទូរស័ព្ទ ៖.......................................................................................................

អ៊ីម៉ែល ៖.......................................................................................................

## ផ្នែកទី២ : មូលហេតុ និងគោលបំណងនៃការស្នើសុំ

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

## ផ្នែកទី៣ : ឈ្មោះផលិតផលដែលស្នើសុំប្តូរពណ៌ស្លាកសញ្ញាហាឡាលកម្ពុជា

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

## ផ្នែកទី៤ : គំរូស្លាកសញ្ញាចាស់ និងថ្មី

Color Code : ....................

Color Code : ....................

គំរូស្លាកសញ្ញា(ចាស់)

គំរូស្លាកសញ្ញា(ថ្មី)

## ផ្នែកទី៥ : ហត្ថលេខារបស់អ្នកស្នើសុំ

*សំគាល់:* ប្រសិនបើផ្នែកនេះត្រូវបានចុះហត្ថលេខាដោយភ្នាក់ងារតំណាងក្នុងនាមអ្នកស្នើសុំ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិមកជាមួយផង ។

(ក) : ហត្ថលេខា :...........................................................................................................

(ខ) : ឈ្មោះ :...........................................................................................................

(គ) : តួនាទី :...........................................................................................................

(ឃ): កាលបរិច្ឆេទ :...........................................................................................................